00647915

E33/2

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ សហមេធាវីការពារក្តីលោក អៀង សារី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **អង់គ្លេស**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ** សាធារណៈ / Public

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សារណាឆ្លើយតបរបស់លោក អៀង សារី ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម នៅក្នុងពេលជំនុំជម្រះ**

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្តី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង យូរ ឧត្តារា

ចៅក្រមបម្រុង Claudia FENZ

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

ឯកសារដើម

DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 24 / 02 / 2011

ម៉ោង (Time/Heure): 15:30

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក អៀង សារី តាមរយៈមេធាវីការពារក្ដីរបស់ខ្លួន (“ក្រុមមេធាវីការពារក្ដី”) សូមធ្វើសារណាឆ្លើយតប ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា[1]ទៅនឹងញត្តិរបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម នៅក្នុងពេលជំនុំជម្រះ (“ញត្តិ”)[2]។ សារណាឆ្លើយតបនេះគឺមានលក្ខណៈចាំបាច់ ដើម្បីកែតម្រូវនូវការថ្លែងមិនត្រឹមត្រូវដែលធ្វើឡើងដោយការិយាល័យសហព្រះរាជ-អាជ្ញា (“កសព”)។ ប៉ុន្តែ ក្រុមមេធាវីការពារក្ដី សូមស្នើសុំការពិចារណាថា បញ្ហានេះជាដើម្បីជាការសមរម្យបំផុតនោះគួរត្រូវយកមកដោះស្រាយ នាពេលកិច្ចប្រជុំរៀបចំសវនាការដែលគ្រោងធ្វើឡើងនាពេលឆាប់ៗខាងមុខនេះ ដែលនៅពេលនោះគ្រប់ភាគីទាំងអស់អាចរួមចំណែកផ្ដល់មតិយោបល់របស់ពួកគេទៅលើបញ្ហានេះជាមួយអង្គជំនុំជម្រះសាលាដំបូង[3]។

## I. **សារណាឆ្លើយតប**

1. កសព អះអាងថា ញត្តិដាក់មិនត្រឹមត្រូវតាមពេលវេលា[4]។ កសព អះអាងថា ការណ៍នេះគឺដោយសារវិធាន៨៧ នៃវិធានផ្ទៃក្នុងអនុញ្ញាតអោយតែអង្គជំនុំជម្រះសាលាដំបូង បដិសេធភស្តុតាង “*លុះត្រាតែ*ភស្តុតាងត្រូវបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ដោយភាគីណាមួយ (វិធាន ៨៧-៣)”។[5] វិធាន ៨៧ មិនចែងដូច្នេះឡើយ។ វិធាន ៨៧(៣) អនុញ្ញាតអោយអង្គជំនុំជម្រះសាលាដំបូងបដិសេធនូវសំណើសុំភស្តុតាង ដោយឈរលើមូលដ្ឋានមួយចំនួន និងចែងថា ធ្វើ

---

[1] សំណុំរឿង អៀង សារី, ០០២/១៩-០៩-២០០៧-អវតក/អជសដ, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងញត្តិរបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម នៅក្នុងពេលជំនុំជម្រះ ចុះថ្ងៃទី ២១ កុម្ភៈ ២០១១ ឯកសារលេខ E33/1, ERN: 00645751-00645753។

[2] សំណុំរឿង អៀង សារី, ០០២/១៩-០៩-២០០៧-អវតក/អជសដ, ញត្តិរបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម នៅក្នុងពេលជំនុំជម្រះ ចុះថ្ងៃទី ៤ កុម្ភៈ ២០១១ ឯកសារលេខ E33, ERN: 00640260-00640275។

[3] ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ ក៏បានស្នើសុំផងដែរថា បញ្ហានេះត្រូវដោះស្រាយនៅកិច្ចប្រជុំរៀបចំសវនាការ។ *សូមមើល* សំណុំរឿង អៀង ធីរិទ្ធ, ០០២/១៩-០៩-២០០៧-អវតក/អជសដ សំណើសុំរបស់មេធាវីការពារក្ដីទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីសម្រេចលើបញ្ហាដែលមានសារៈសំខាន់ដល់ចុងចោទទាំងអស់ ចុះថ្ងៃទី ១០ កុម្ភៈ ២០១១ ឯកសារលេខ E39, ERN: 00643391-00643396។

[4] ចម្លើយតប កថាខណ្ឌ ១។

[5] ដូចខាងលើ កថាខណ្ឌ ២។

សេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់ចំពោះមុខខ្លួន។ គ្មានអ្វីនៅក្នុងវិធានផ្ទៃក្នុងនេះហាមឃាត់លទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបដិសេធភស្តុតាងនាដំណាក់កាលនេះ នៅមុនពេលដែលវាត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលជំនុំជម្រះ។

2. កសព អះអាងថា "ការកំណត់ថាតើភស្តុតាងណាមួយ ត្រូវទទួលយក ឬបដិសេធ អាចធ្វើទៅបាន លុះត្រាតែវាមានប្រយោជន៍ នៅពេលអង្គជំនុំជម្រះសាលាដំបូងមានឱកាសពិនិត្យភស្តុតាង និងស្តាប់ចម្លើយរបស់ភាគីនានា។"[6] ចំណុចនេះមិនត្រឹមត្រូវឡើយ។ មេធាវីការពារក្តីបានស្នើសុំអោយអង្គជំនុំជម្រះសាលាដំបូង អោយបង្គាប់ដល់ភាគីនានាកុំអោយប្រើប្រាស់នូវភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម លុះត្រាតែភាគីនោះជាដំបូងអាចចង្អុលបង្ហាញថា ភស្តុតាងប្រភេទនេះគឺត្រូវបានយកមកប្រើប្រឆាំងនឹងបុគ្គល ដែលត្រូវបានចោទប្រកាន់ចំពោះការធ្វើទារុណកម្ម ថាជាភស្តុតាងបង្ហាញថាសេចក្តីថ្លែងការណ៍ត្រូវបានធ្វើឡើងមែន។ ភស្តុតាងជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម គឺមិនត្រូវបានគេអនុញ្ញាតអោយយកមកប្រើក្នុងគោលបំណងណាផ្សេងពីនេះ[7]។ វាគ្មានហេតុផលណាត្រូវពិនិត្យលើភស្តុតាង ដើម្បីកំណត់ថាតើវាត្រូវដកចេញដែរឬអត់នោះ បើសិនជាវាមិនត្រូវបានយកមកប្រើសម្រាប់គោលបំណងតែមួយមុខដែលគេអនុញ្ញាតនោះ។ វានឹងមានលក្ខណៈកាន់តែងាយស្រួល និងមានប្រសិទ្ធិភាពឡើងក្នុងសម្រេចតាំងពីដើមទីទៅថា ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម មិនត្រូវដាក់បញ្ចូល លុះត្រាតែវាត្រូវបានប្រើប្រាស់សម្រាប់តែក្នុងគោលបំណងតែមួយមុខដែលគេអនុញ្ញាតនេះ និងតម្រូវអោយភាគីទាំងឡាយចង្អុលបង្ហាញថា ពួកគេមានបំណងប្រើប្រាស់ភស្តុតាងនេះសម្រាប់តែក្នុងគោលបំណងតែមួយមុខនេះប៉ុណ្ណោះ។

3. កសព អះអាងថា នៅក្នុងសំណុះរឿង ០០១ ការអនុវត្តចំពោះការទទួលយក និងការបដិសេធភស្តុតាង គឺត្រូវបានធ្វើឡើង បន្ទាប់ពីភស្តុតាងត្រូវបានគេស្នើសុំអោយទទួលយកដោយភាគីនានា។

---

[6] ដូចខាងលើ កថាខណ្ឌ ៣២។

[7] សំណុំរឿង អៀង សារី, ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣១) សាលដីកាស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ កសចស លើសំណើសុំរបស់ អៀង សារី ចុះថ្ងៃទី ១០ ឧសភា ២០១០ ឯកសារលេខ D130/7/3/5, ERN: 00512912-00512924 កថាខណ្ឌ ៣៨ ដែលថ្លែងថា "មាត្រា១៥ នៃ [អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម] ត្រូវយកមកប្រើអោយបានតឹងរឹង។ មិនមានចន្លោះណាសម្រាប់ការកំណត់អំពីភាពត្រឹមត្រូវ ឬ សម្រាប់ការប្រើប្រាស់ផ្ទុយពីនេះនូវសេចក្តីថ្លែងការណ៍ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម"។

ករណីនេះអាចត្រឹមត្រូវ ប៉ុន្តែវាមិនរារាំងអង្គជំនុំជម្រះសាលាដំបូង មិនអោយចេញដីកាបង្គាប់នៅមុនពេលចាប់ផ្តើមការជំនុំជម្រះឡើយ។ វិធានផ្ទៃក្នុង មិនហាមឃាត់អង្គជំនុំជម្រះសាលាដំបូង មិនអោយចាត់វិធានការនេះទេ ហើយដោយពិចារណាឃើញថា ករណី ០០២ នឹងមានទំហំធំជាង និងស្មុគស្មាញជាងករណី ០០១ វាជាការប្រសើរដែលត្រូវអោយគេដោះស្រាយបញ្ហានេះនាពីដំបូងដែរទៅ។

4. កសព កត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាបង្គាប់អោយភាគីនានាដាក់នូវបញ្ជីនៃឯកសារ និងភស្តុតាង ដែលភាគីទាំងនោះស្នើសុំអោយទទួលយកនាពេលជំនុំជម្រះក្តីនៅត្រឹមថ្ងៃទី ១៣ មេសា ២០១១ ហើយវិធាន ៨០(៤) បន្ទាប់មកអនុញ្ញាតអោយ អង្គជំនុំជម្រះសាលាដំបូង ចេញដីកាបង្គាប់អោយភាគីដាក់នូវការជំទាស់នៅក្នុងរយៈពេលកំណត់។ កសព ស្នើអង្គជំនុំជម្រះសាលាដំបូង អោយបដិសេធចោលញត្តិនេះដោយសារវាដាក់មិនត្រឹមត្រូវតាមពេលវេលា និងចេញដីកាដូចមានចែងក្នុងវិធាន ៨០(៤) ដើម្បីអនុញ្ញាតអោយភាគីលើកឡើងការជំទាស់នឹងភស្តុតាង ដែលស្នើដោយភាគីដទៃទៀតនៅក្នុងរយៈពេលកំណត់បន្ទាប់ពីសវនាការបឋម។ ក្រុមមេធាវីការពារក្តី យល់ស្របថា អង្គជំនុំជម្រះសាលាដំបូង គួរអនុញ្ញាតអោយភាគីដាក់ការជំទាស់ទៅនឹងបញ្ជីឯកសារ និងភស្តុតាង ដែលភាគីដទៃទៀតដាក់នៅថ្ងៃទី ១៣ មេសា ២០១១ ។ ប៉ុន្តែវានឹងមិនដោះស្រាយបញ្ហានេះទេ។ ការជំទាស់នឹង ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម នឹងមិនអាចធ្វើទៅបានបើសិនជាមិនដឹងពីគោលបំណងដែលភស្តុតាងនោះត្រូវបានស្នើសុំអោយទទួលយក។ ភាគីនានា ត្រូវតែបានគេបង្គាប់កុំអោយប្រើប្រាស់ ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម លុះត្រាតែពួកគេអាចចង្អុលបង្ហាញថា វាកំពុងត្រូវបានប្រើប្រាស់ប្រឆាំងនឹងបុគ្គល ដែលត្រូវបានចោទប្រកាន់ចំពោះការធ្វើទារុណកម្ម ថាជាភស្តុតាងបង្ហាញថាសេចក្តីថ្លែងការណ៍ត្រូវបានធ្វើឡើងមែន។

## II. សំណើសុំ

ហេតុដូច្នេះ ដូចហេតុផលបានលើកឡើងនៅក្នុងញត្តិនេះ និងសេចក្តីបញ្ជាក់នេះ ក្រុមមេធាវីការពារក្តីស្នើសុំដោយគោរពកុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាលើភស្តុតាង ដែលជាប់ពាក់ព័ន្ធនឹងទារុណកម្ម លើកលែងតែជាភស្តុតាងប្រឆាំងនឹងជនដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើទារុណកម្ម ដើម្បីបញ្ជាក់ថាសេចក្តីថ្លែងការណ៍នោះពិតជាត្រូវបានធ្វើឡើងមែន ហើយបង្គាប់អោយភាគីកុំឱ្យប្រើប្រាស់

ភស្តុតាងបែបនេះ លើកលែងតែភាគីបង្ហាញថា ភស្តុតាងទាំងនេះនឹងយកមកប្រើប្រាស់ក្នុងគោលបំណងនេះតែមួយគត់។

សូមលោកសហចៅក្រមទទួលយកសារណាឆ្លើយតបនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១១

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី